# សៀវភៅមគ្គុទេសក៍

## ស្តីពី
## ការប្រើប្រាស់កម្មវិធីវេបផតថល និង កម្មវិធីទូរស័ព្ទ
## ថ្នាលឌីជីថលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ



# មាតិកា


- ១. ហេតុអ្វីត្រូវចុះឈ្មោះជាប្រជាជន ឬ សហគ្រាស ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ? ០១
- ២. នរណាអាចចុះឈ្មោះបាន? ០១
- ៣. វិធីសាស្រ្តចុះឈ្មោះ ០២
  - ៣.១. តម្រូវការឯកសារ និង ព័ត៌មាន ០៣
  - ៣.២. របៀបចុះឈ្មោះតាមកម្មវិធីទូរស័ព្ទដៃ ០៤
  - ៣.៣. របៀបចុះឈ្មោះតាមផតថល ១០
  - ៣.៤. របៀបចុះឈ្មោះតាមដៃគូភ្ជាក់ងារ ១៦
- ៤. ការទទួលបានស្ថានភាពទទួលស្គាល់ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ១៨
- ៥. មុខងារផ្សេងៗ ២០
  - ៥.១. កម្មវិធីទូរស័ព្ទដៃ CamIE ២០
    - ៥.១.១. មុខងារបញ្ជូនត្រលប់ និង ដាក់ស្នើម្តងទៀត ២០
    - ៥.១.២. មុខងារទាញយកវិញ្ញាបនបត្រ ២៣
    - ៥.១.៣. មុខងារផ្លាស់ប្តូរកូដសម្ងាត់ ២៤
    - ៥.១.៤. ទំព័រដើម ២៥
    - ៥.១.៥. ជំនួយ ២៥
    - ៥.១.៦. ដំណឹង ២៦
    - ៥.១.៧. ការកំណត់ ២៦
  - ៥.២. កម្មវិធីវេបផតថល CamIE ២៧
    - ៥.២.១. មុខងារបញ្ជូនត្រលប់ និង ដាក់ស្នើម្តងទៀត ២៧
    - ៥.២.២. មុខងារទាញយកវិញ្ញាបនបត្រ ៣០
    - ៥.២.៣. មុខងារផ្លាស់ប្តូរកូដសម្ងាត់ ៣២
    - ៥.២.៤. ទំព័រដើម ៣៣
    - ៥.២.៥. ជំនួយ ៣៤
    - ៥.២.៦. ដំណឹង ៣៥
    - ៥.២.៧. ការកំណត់ ៣៦
  - ឧបសម្ព័ន្ធទី ១ ៖ សេចក្តីសម្រេច ១០០ សសរ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការផ្ទេរការផ្តល់សេវារដ្ឋបាលមួយចំនួន របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ៣៧

**ហាមថតចម្លង**
រក្សាសិទ្ធិឆ្នាំ ២០២៤ ដោយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល

**រក្សាសិទ្ធិគ្រប់យ៉ាង**
បោះពុម្ពដោយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល
បោះពុម្ពផ្សព្វផ្សាយលើកទី ១ នៅឆ្នាំ ២០២៤
អគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច, ផ្លូវមហាវិថី OCIC, សង្កាត់ជ្រោយចង្វារ, ខណ្ឌជ្រោយចង្វារ,
រាជធានីភ្នំពេញ, ប្រទេសកម្ពុជា

# ✤ ១. ហេតុអ្វីត្រូវចុះឈ្មោះជាប្រជាជន ឬ សហគ្រាស ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ?

- ដើម្បីទទួលបានការលើកទឹកចិត្ត ផ្នែកពន្ធដារ
- ដើម្បីទទួលបានការបណ្តុះបណ្តាល ពង្រឹង និង ពង្រីកអាជីវកម្ម
- ដើម្បីទទួលបានអត្ថប្រយោជន៍ ផ្នែកថែទាំសុខភាព
- ដើម្បីទទួលបានកញ្ចប់អត្ថប្រយោជន៍ ផ្សេងទៀតពីរាជរដ្ឋាភិបាល

# ✤ ២. នរណាអាចចុះឈ្មោះបាន?

១ សហគ្រាសធុនមីក្រូដែលមិនមាន ទីតាំងអាជីវកម្មច្បាស់លាស់



២ សេចក្តីសម្រេច ១០០ សសរ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការផ្អាកការ ផ្តល់សេវារដ្ឋបាលមួយចំនួន របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ



៣ កម្មករ និយោជិតនៃសហគ្រាសខាងលើ



៤ បុគ្គលស្វ័យនិយោជន៍ដែលមិនមាន ទីតាំងអាជីវកម្មច្បាស់លាស់



## ✦ ៣. វិធីសាស្ត្រចុះឈ្មោះ

ការចុះឈ្មោះមានច្រើនវិធីសាស្ត្រ ហើយអាចសម្រេចទៅបាន ក្នុងរយៈពេលត្រឹមតែ ៥ នាទីតែប៉ុណ្ណោះ។



ចុះឈ្មោះដោយខ្លួនឯងតាមរយៈ

### កម្មវិធីទូរស័ព្ទដៃ ឬ វេបផតថល

ចុះឈ្មោះតាមរយៈ

### ភ្នាក់ងារជាដៃគូ




ការិយាល័យច្រកចេញចូលតែមួយថ្នាក់ក្រុង ស្រុក ខណ្ឌ



បេឡាជាតិសន្តិសុខសង្គម




ភ្នាក់ងារ និង សាខាធនាគារវីង




ធនាគារអេស៊ីលីដា

## ៣.១. តម្រូវការឯកសារ និង ព័ត៌មាន

### សហគ្រាសដែលមិនមានទីតាំងអាជីវកម្មច្បាសលាស់

ទិន្នន័យអត្តសញ្ញាណរបស់ម្ចាស់ និង ទិន្នន័យសេដ្ឋកិច្ច



អត្តសញ្ញាណប័ណ្ណច្បាប់ដើម



រូបថតសេលហ្វីម្ចាស់ជាមួយសហគ្រាស



រូបថតសកម្មភាពអាជីវកម្ម



### កម្មករ និយោជិត ឬ បុគ្គស្វ័យនិយោជន៍ នៃសហគ្រាសធុនមីក្រូដែលមិនមានទីតាំងអាជីវកម្មច្បាស់លាស់

ទិន្នន័យអត្តសញ្ញាណ, ទិន្នន័យសេដ្ឋកិច្ច និង ទិន្នន័យអប់រំ



អត្តសញ្ញាណប័ណ្ណច្បាប់ដើម



រូបថតសេលហ្វីជាមួយសហគ្រាស ឬ អាជីវកម្ម



រូបថតសហគ្រាស ឬ សកម្មភាពអាជីវកម្ម



## ៣.២. របៀបចុះឈ្មោះតាមកម្មវិធីទូរស័ព្ទដៃ

- ចូលក្នុង App Store ឬ Google Play store រួចទាញយកកម្មវិធីទូរស័ព្ទដៃ **CamIE**។



**ទាញយកកម្មវិធីទូរស័ព្ទ**

**CamIE**

Download on the App Store

GET IT ON Google Play




១

- ចូលទៅកាន់កម្មវិធីទូរស័ព្ទដៃ CamIE។ ជ្រើសរើស **“ភាសាខ្មែរ”**។




២

- ចុច **“ចាប់ផ្តើម”** រួចចុច **“បង្កើតគណនីថ្មី”** ដើម្បីបង្កើតគណនីប្រើប្រាស់ថ្មី។




៣

- បញ្ចូលលេខទូរស័ព្ទ ឬ អ៊ីម៉ែល រួចបង្កើតលេខសម្ងាត់ និងបញ្ជាក់លេខសម្ងាត់របស់លោកអ្នក។លេខសម្ងាត់ត្រូវមានយ៉ាងតិច ៦ តួអក្សរ ដែលតម្រូវឱ្យមានអក្សរតូច អក្សរធំ និងលេខ។

៤

- អានគោលការណ៍ឯកជនភាព និង ☑ នៅលើប្រអប់ដើម្បីអះអាងថាពិតជាបានអាន និងយល់ព្រមលើគោលការណ៍ឯកជនភាព រួចចុចប៊ូតុង **“បង្កើតគណនីថ្មី”**។

## ៥




- បញ្ចូលលេខកូដ (**One-Time Passcode – OTP**) ចំនួន ៦ ខ្ទង់ ដែលបានផ្ញើទៅកាន់លេខទូរស័ព្ទ ឬ អ៊ីម៉ែល។ ប្រសិនបើពុំទទួលបានលេខកូដ ៦ខ្ទង់ ពីប្រព័ន្ធក្នុងរយៈពេល ៦០ វិនាទីនោះទេ ចុច **“ផ្ញើឡើងវិញ”** ដើម្បីទទួលបានលេខកូដថ្មី។

## ៦




- ចុច **“ថតរូប”** ដើម្បីថតរូបអត្តសញ្ញាណប័ណ្ណរបស់លោកអ្នកចេញពីច្បាប់ដើម។

## ៧




- ថតរូបសែលហ្វីរបស់លោកអ្នក។ ហាមពាក់ម៉ាស់ មួក និង/ឬ វ៉ែនតាក្នុងអំឡុងពេលថតរូប និង ជៀសវាងរូបភាពឃើញមុខមិនច្បាស់ ឬ មានអ្នកផ្សេងនៅផ្នែកខាងក្រោយនៃរូបថត។







## ៨

- ផ្ទៀងផ្ទាត់ព័ត៌មានអត្តសញ្ញាណរបស់លោកអ្នកដែលត្រូវបានបំពេញដោយស្វ័យប្រវត្តិ។ កែតម្រូវប្រសិនបើមានខុស។ រួចចុច **“បន្ត”**។







## ៩

- ចុចលើសញ្ញាបូក ⊕ រួចជ្រើសរើសកម្មករ និយោជិត, សហគ្រាស ឬ បុគ្គលស្វ័យនិយោជន៍។

## ១០

- ជ្រើសរើស កម្មករ និយោជិតនៃសហគ្រាស មិនមានទីតាំងអាជីវកម្មច្បាស់លាស់ប្រសិន បើលោកអ្នកបម្រើការងារឱ្យសហគ្រាស។
- ជ្រើសរើស សហគ្រាសមិនមានទីតាំង អាជីវកម្មច្បាស់លាស់ ប្រសិនបើលោកអ្នក ជាម្ចាស់សហគ្រាស ឬ អាជីវកម្មដែលមាន បុគ្គលិកបម្រើការ។ ប្រសិនបើលោកអ្នក បំពេញពាក្យស្នើសុំក្នុងនាមជាសហគ្រាស, លោកអ្នកនឹងតម្រូវឱ្យបញ្ចូលរូបថតសែលហ្វីជាមួយទីតាំងអាជីវកម្ម និង រូបថតសកម្មភាពអាជីវកម្ម។
- ជ្រើសរើស បុគ្គលស្វ័យនិយោជន៍មិនមាន ទីតាំងអាជីវកម្មច្បាស់លាស់ ប្រសិនបើលោកអ្នកធ្វើការដោយខ្លួនឯង និង មិនមានបុគ្គលិកបម្រើការ។






## ១១

- បំពេញទម្រង់បែបបទដែលនៅសេសសល់ឱ្យបានត្រឹមត្រូវ។

## ១២

- អានបទប្បញ្ញត្តិ និង លក្ខខណ្ឌដើម្បីអះអាងថាលោកអ្នកពិតជាបានផ្តល់ព័ត៌មានពិតប្រាកដមែន។

## ១៣

- ចុចប៊ូតុង☑ នៅក្នុងប្រអប់រួចចុចប៊ូតុង “ផ្ញើឡើងវិញ” ជាការស្រេច។









## លោកអ្នកនឹងអាចចូលទៅ (Log In)

ក្នុងកម្មវិធីទូរស័ព្ទដៃ ដើម្បីទទួលបានស្ថានភាពចុងក្រោយនៃការស្នើសុំចុះឈ្មោះជាប្រជាជនក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

សូមរង់ចាំយ៉ាងយូរ ៨ ម៉ោង នៃម៉ោងធ្វើការ ដើម្បីឱ្យមន្ត្រីមានសមត្ថកិច្ច ផ្ទៀងផ្ទាត់ និង ត្រួតពិនិត្យពាក្យស្នើសុំរបស់លោកអ្នក។

## • ៣.៣. របៀបចុះឈ្មោះតាមផតថល

**១.** ចូលទៅកាន់តំណភ្ជាប់ ie.debc.gov.kh/self-registration/register ឬ ទាញយកកម្មវិធីវេបផតថលតាមរយៈឃ្យូអរកូត ដើម្បីចូលទៅកាន់វេបផតថលនៃថ្នាលចុះឈ្មោះប្រជាជនក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

ស្កេនតាមរយៈ
**QR កូដនេះ**



**២.** ចុចប៊ូតុង **"បង្កើតគណនីថ្មី"** ដើម្បីបង្កើតគណនីប្រើប្រាស់។



**៣.** បញ្ចូលលេខទូរស័ព្ទ រួចបង្កើតលេខសម្ងាត់ (យ៉ាងតិច ៦ តួអក្សរ ដែលតម្រូវឱ្យមានអក្សរតូច អក្សរធំ និង លេខ)។

**៤.** សូមអានគោលការណ៍ឯកជនភាព និង ☑ នៅលើប្រអប់ដើម្បីអះអាងពិតជាបានអាន និងយល់ព្រមលើគោលការណ៍ឯកជនភាព រួចចុចប៊ូតុង **“បង្កើតគណនីថ្មី”**។



**៥.** បញ្ចូលលេខកូដ (One-Time Passcode – OTP) ចំនួន ៦ ខ្ទង់ ដែលបានផ្ញើទៅកាន់លេខទូរស័ព្ទ ឬ អ៊ីម៉ែល។ ប្រសិនបើពុំទទួលបានលេខកូដ ៦ខ្ទង់ ពីប្រព័ន្ធក្នុងរយៈពេល ៦០ វិនាទី នោះទេចុច **“ផ្ញើឡើងវិញ”** ដើម្បីទទួលបានលេខកូដថ្មី។




**៦.** បញ្ចូលអត្តសញ្ញាណប័ណ្ណច្បាប់ដើមរបស់លោកអ្នកជាទម្រង់ PNG, JPG, JPEG។



**៧.** បញ្ចូលរូបថតរបស់លោកអ្នក ដោយចុច **“បញ្ចូល”**។ រូបថតត្រូវតែច្បាស់ និង មិនត្រូវមានការពាក់ម៉ាស់ មួក និង/ឬ វ៉ែនតាទេ។



- ផ្ទៀងផ្ទាត់ព័ត៌មានអត្តសញ្ញាណរបស់លោកអ្នកដែលត្រូវបានបំពេញដោយស្វ័យប្រវត្តិ។ កែតម្រូវប្រសិនបើមានខុស។

**៨.** បំពេញទម្រង់បែបបទដែលនៅសេសសល់ឱ្យបានត្រឹមត្រូវ រួចចុច **“បន្ទាប់”**។



**៩.** ជ្រើសរើសកម្មករ និយោជិត, សហគ្រាស ឬ បុគ្គលស្វ័យនិយោជន៍។

ជ្រើសរើសកម្មករ និយោជិត ប្រសិនបើលោកអ្នកបម្រើការងារឱ្យសហគ្រាស។

ជ្រើសរើសសហគ្រាស ប្រសិនបើលោកអ្នកជាម្ចាស់សហគ្រាស ឬ អាជីវកម្មដែលមានបុគ្គលិកបម្រើការ។ ប្រសិនបើលោកអ្នកបំពេញពាក្យស្នើសុំក្នុងនាមជាសហគ្រាស, លោកអ្នកនឹងតម្រូវឱ្យបញ្ចូលរូបថតសែលហ្វីជាមួយទីតាំងអាជីវកម្ម និង រូបថតសកម្មភាពអាជីវកម្ម។

ជ្រើសរើសបុគ្គលស្វ័យនិយោជន៍ ប្រសិនបើលោកអ្នកធ្វើការដោយខ្លួនឯង មិនមានបុគ្គលិកបម្រើការ។




**១០.** បំពេញទម្រង់បែបបទដែលនៅសេសសល់ឱ្យបានត្រឹមត្រូវ រួចចុច **"បន្ទាប់"**។

**១១.** ផ្ទៀងផ្ទាត់ព័ត៌មានដែលបានបំពេញសារឡើងវិញ។




**១២.** អានបទប្បញ្ញត្តិ និង លក្ខខណ្ឌដើម្បីអះអាងថាលោកអ្នកពិតជាបានផ្តល់ព័ត៌មានពិតប្រាកដមែន។

**១៣.** ចុចប៊ូតុង ☑ នៅក្នុងប្រអប់ រួចចុចប៊ូតុង **“ចុះឈ្មោះ”** ជាការស្រេច។



- លោកអ្នកនឹងអាចចូលទៅ (Log In) កាន់ផតថល ដើម្បីទទួលបានស្ថានភាពចុងក្រោយនៃការស្នើសុំចុះឈ្មោះជាប្រជាជនក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ សូមរង់ចាំយ៉ាងយូរ ៨ ម៉ោង ដើម្បីមន្ត្រីមានសមត្ថកិច្ច ផ្ទៀងផ្ទាត់ និង ត្រួតពិនិត្យពាក្យស្នើសុំរបស់លោកអ្នក។

## ៣.៤. របៀបចុះឈ្មោះតាមដៃគូភ្នាក់ងារ

ក្នុងករណីលោកអ្នកមិនអាចចុះឈ្មោះដោយខ្លួនឯង តាមរយៈកម្មវិធីទូរស័ព្ទដៃ និង វេបផតថលបាន លោកអ្នកក៏អាចចុះឈ្មោះបានតាមដៃគូភ្នាក់ងាររបស់យើងខ្ញុំ ដែលមានដូចជា មណ្ឌលចុះឈ្មោះចល័ត, ការិយាល័យច្រកចេញចូលតែមួយថ្នាក់ក្រុង ស្រុក ខណ្ឌ, សាខាបេឡាជាតិសន្តិសុខសង្គម, គ្រប់ភ្នាក់ងារ និង សាខាធនាគារវីង។

### ឯកសារដែលត្រូវត្រៀមសម្រាប់ការចុះឈ្មោះតាមដៃគូភ្នាក់ងារ



អត្តសញ្ញាណប័ណ្ណច្បាប់ដើម




ក្នុងករណីចុះឈ្មោះជាសហគ្រាស តម្រូវឱ្យមានរូបថតសែលហ្វីរបស់អ្នកជាមួយទីតាំងសហគ្រាស និង រូបថតសកម្មភាពអាជីវកម្ម។ បម្រើការងារ, អាជីវកម្ម, និង មុខរបរដែលមានស្រាប់ក្នុងទូរស័ព្ទដៃរបស់លោកអ្នក



ក្នុងករណីចុះឈ្មោះជាកម្មករនិយោជិត និង បុគ្គលស្វ័យនិយោជន៍ តម្រូវឱ្យមានរូបថតសែលហ្វីរបស់អ្នកជាមួយទីតាំងសហគ្រាសបម្រើការងារ ឬ អាជីវកម្ម និង រូបថតទីតាំងសហគ្រាសបម្រើការងារ ឬ សកម្មភាពអាជីវកម្ម ដែលមានស្រាប់ក្នុងទូរស័ព្ទដៃរបស់លោកអ្នក

ភ្នាក់ងារជាដៃគូនឹងផ្តល់កូដសម្ងាត់ដល់លោកអ្នក ដើម្បីលោកអ្នកអាចតាមដានស្ថានភាពនៃពាក្យស្នើសុំ តាមរយៈការចូលទៅ (Log In) កាន់វេបផតថល ឬ កម្មវិធីទូរស័ព្ទដៃ។ សូមស្នើសុំជំនួយពីដៃគូភ្នាក់ងាររបស់យើងខ្ញុំ ក្នុងករណីលោកអ្នកមិនអាច ឬ មិនមានមធ្យោបាយក្នុងការតាមដានពាក្យស្នើសុំដូចបានរៀបរាប់ខាងលើ។

# សូមចូលទៅកាន់

**www.ie.digitaleconomy.gov.kh**

ដើម្បីស្វែងរកទីតាំងដៃគូភ្នាក់ងារ
ដែលនៅជិតលោកអ្នកបំផុត។



## ✤ ៤. ការទទួលបានស្ថានភាពទទួលស្គាល់ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ

ក្រោយការចុះឈ្មោះជាប្រជាជនក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធតាមរយៈវិធីសាស្ត្រណាមួយខាងលើបានជោគជ័យ និង ទទួលបានការអនុម័តពីមន្ត្រីជំនាញមានសមត្ថកិច្ច, លោកអ្នកនឹងទទួលបានស្ថានភាពទទួលស្គាល់ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ នៅពេលចូលទៅ (Log In)កាន់វេបផតថល ឬ កម្មវិធីទូរស័ព្ទដៃ, លោកអ្នកអាចទាញយកនូវវិញ្ញាបនបត្របញ្ជាក់ពីស្ថានភាពទទួលស្គាល់ជាប្រជាជន និង សហគ្រាសក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ

ដើម្បីមករក្សាទុកក្នុងឧបករណ៍អេឡិចត្រូនិកណាមួយរបស់លោកអ្នក។ វិញ្ញាបនបត្រឌីជីថលនេះមានតម្លៃសមមូលនឹងវិញ្ញាបនបត្ររូបវ័ន្ត ហើយក្នុងករណីបាត់បង់ លោកអ្នកនៅតែអាចទាញយកវិញ្ញាបនបត្រនៅពេលណាក៏បាន គ្រប់ទីកន្លែងតាមរយៈផតថល ឬកម្មវិធីទូរស័ព្ទដៃ (សូមអានផ្នែក ៥.១.២. និង ផ្នែក ៥.២.២. សម្រាប់របៀបនៃការទាញយកវិញ្ញាបនបត្រ)។

តាមរយៈការផ្តល់ទិន្នន័យរបស់លោកអ្នក, លោកអ្នកនឹងអាចទទួលបានកញ្ចប់អត្ថប្រយោជន៍ជាច្រើន ដែលរាជរដ្ឋាភិបាលរៀបចំឡើង ផ្អែកតាមតម្រូវការ និង ប្រជាសាស្ត្ររបស់លោកអ្នក។

## ដើម្បីទទួលបានព័ត៌មានពីកញ្ចប់អត្ថប្រយោជន៍ និង ព័ត៌មានផ្សេងទៀត ពីសេដ្ឋកិច្ចក្រៅប្រព័ន្ធ

**សូមតាមដានគេហទំព័រ**
www.ie.digitaleconomy.gov.kh
និង ទំព័រហ្វេសប៊ុក (Facebook),
ឆាណែលតេលេក្រាម (Telegram), តិកតុក (Tik Tok)
និង យូធូប (YouTube)
ថ្នាលឌីជីថលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ។



# ៥. មុខងារផ្សេងៗ

## ៥.១. កម្មវិធីទូរស័ព្ទដៃ CamIE

### ៥.១.១. មុខងារបញ្ជូនត្រលប់ និង ដាក់ស្នើម្តងទៀត

ក្នុងករណីព័ត៌មានដែលបានដាក់ស្នើសុំមិនត្រឹមត្រូវ ឬ ត្រូវការកែតម្រូវ, ពាក្យស្នើសុំរបស់លោកអ្នកនឹងត្រូវបានបញ្ជូនត្រលប់មកវិញ។ ក្នុងករណីនេះ, សូមចូលទៅកាន់កម្មវិធីទូរស័ព្ទដៃ រួចធ្វើតាមការណែនាំខាងក្រោម៖




- ពិនិត្យលើមូលហេតុបញ្ជូនត្រលប់ រួចចុច **“ពិនិត្យឡើងវិញ”**។

- កែតម្រូវទិន្នន័យអត្តសញ្ញាណ ប្រសិនបើបំពេញខុស រួចចុច **“បន្ទាប់”**។



• កែតម្រូវទិន្នន័យសេដ្ឋកិច្ច និង ទិន្នន័យអប់រំ ប្រសិនបើបំពេញខុស រួចចុច **"បន្ទាប់"**។












• ផ្ទៀងផ្ទាត់ព័ត៌មានដែលបានបំពេញសារឡើងវិញ។

• អានបទប្បញ្ញត្តិ និង លក្ខខណ្ឌដើម្បីអះអាងថាលោកអ្នកពិតជាបានផ្តល់ព័ត៌មានពិតប្រាកដមែន។
• ចុចប៊ូតុង ☑ នៅក្នុងប្រអប់ដើម្បីអះអាងថា លោកអ្នកពិតជាបានផ្តល់ព័ត៌មានត្រឹមត្រូវ និង ពិតប្រាកដមែន រួចចុច **"ចុះឈ្មោះម្តងទៀត"** ជាការស្រេច។
• សូមរង់ចាំយ៉ាងយូរ ៨ ម៉ោង នៃម៉ោងធ្វើការដើម្បីមន្ត្រីមានសមត្ថកិច្ចផ្ទៀងផ្ទាត់ និង ត្រួតពិនិត្យពាក្យស្នើសុំរបស់លោកអ្នក។






# ៥.១.២. មុខងារទាញយកវិញ្ញាបនបត្រ

- ចុចសញ្ញា ដើម្បីទាញយកវិញ្ញាបនបត្ររបស់លោកអ្នក។






# ៥.១.៣. មុខងារផ្លាស់ប្តូរកូដសម្ងាត់







• ចុច **“ការកំណត់”** រួចចុច **“ប្តូរកូដសម្ងាត់”**។
• ក្នុងករណីភ្លេចកូដសម្ងាត់ ចុច **“ចូលប្រើប្រាស់”** រួចចុច **“ភ្លេចពាក្យសម្ងាត់”**។
• បញ្ចូលលេខទូរស័ព្ទដែលធ្លាប់បានប្រើប្រាស់សម្រាប់ការស្នើសុំ។







• បញ្ចូលលេខកូដ (One-Time Passcode- OTP) ចំនួន ៦ ខ្ទង់ ដែលបានផ្ញើទៅកាន់លេខទូរស័ព្ទ។ ប្រសិនបើពុំទទួលបានលេខកូដ ៦ខ្ទង់ ពីប្រព័ន្ធក្នុងរយៈពេល ៦០ វិនាទី នោះទេ សូមចុច **“ផ្ញើឡើងវិញ”** ដើម្បីទទួលបានលេខកូដថ្មី។
• បង្កើតកូដសម្ងាត់ថ្មី រួចបញ្ចូលកូដសម្ងាត់ម្តងទៀត ដើម្បីបញ្ជាក់ភាពត្រឹមត្រូវ។
• អានបទប្បញ្ញត្តិ និង លក្ខខណ្ឌដើម្បីអះអាងថាលោកអ្នកពិតជាបានផ្តល់ព័ត៌មានពិតប្រាកដមែន។
• ចុចប៊ូតុង ☑ នៅក្នុងប្រអប់រួចចុចប៊ូតុង **“រួចរាល់”**។

## ៥.១.៤. ទំព័រដើម




នៅលើទំព័រដើមនៃកម្មវិធីទូរស័ព្ទដៃ, លោកអ្នកនឹងអាចតាមដានស្ថានភាពនៃពាក្យស្នើសុំ និង តាមដានសេចក្ដីជូនដំណឹង និងព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

## ៥.១.៥. ជំនួយ

- ចុច “ជំនួយ” នៅផ្នែកខាងក្រោមនៃកម្មវិធីទូរស័ព្ទដៃ ដើម្បីស្វែងរកមធ្យោបាយទាក់ទងមកកាន់ក្រុមការងារ ក្នុងករណីមានចម្ងល់ ឬ បញ្ហាផ្សេងៗ។



## ៥.១.៦. ដំណឹង




- ចុច “ដំណឹង” នៅផ្នែកខាងក្រោមនៃកម្មវិធីទូរស័ព្ទដៃ ដើម្បីទទួលបានដំណឹងផ្សេងៗ។

## ៥.១.៧. ការកំណត់




- ចុច “ការកំណត់” នៅផ្នែកខាងក្រោមនៃកម្មវិធីទូរស័ព្ទដៃ ដើម្បីស្វែងរកព័ត៌មានអត្តសញ្ញាណរបស់លោកអ្នកដែលបានចុះឈ្មោះជាមួយយើងខ្ញុំ និង គោលការណ៍ឯកជនភាព និង លក្ខខណ្ឌ។
- ចុច “ចាកចេញ” ដើម្បីចាកចេញ (Log Out) ពីគណនីរបស់លោកអ្នក។

## ៥.២. កម្មវិធីវេបផតថល CamIE

### ៥.២.១. មុខងារបញ្ជូនត្រលប់ និង ដាក់ស្នើម្តងទៀត

ក្នុងករណីព័ត៌មានដែលបានដាក់ស្នើសុំមិនត្រឹមត្រូវ ឬ ត្រូវការកែតម្រូវ, ពាក្យស្នើសុំរបស់លោកអ្នកនឹងត្រូវបានបញ្ជូនត្រលប់មកវិញ។ ក្នុងករណីនេះ, សូមចូលទៅកាន់កម្មវិធីទូរស័ព្ទដៃ រួចធ្វើតាមការណែនាំខាងក្រោម៖

- ពិនិត្យលើមូលហេតុបញ្ជូនត្រលប់ រួចចុច **"ពិនិត្យឡើងវិញ"**។



- កែតម្រូវទិន្នន័យអត្តសញ្ញាណ ទិន្នន័យសេដ្ឋកិច្ច និង ទិន្នន័យអប់រំ ប្រសិនបើបំពេញខុស រួចចុច **“បន្ទាប់”**។




- ផ្ទៀងផ្ទាត់ព័ត៌មានដែលបានបំពេញសារឡើងវិញ។
- អានបទប្បញ្ញត្តិ និង លក្ខខណ្ឌដើម្បីអះអាងថាលោកអ្នកពិតជាបានផ្តល់ព័ត៌មានពិតប្រាកដមែន។
- ចុច ☑ នៅក្នុងប្រអប់ ដើម្បីអះអាងថា លោកអ្នកពិតជាបានផ្តល់ព័ត៌មានត្រឹមត្រូវ និង ពិតប្រាកដមែន រួចចុច **“ចុះឈ្មោះម្តងទៀត”** ជាការស្រេច។



- លោកអ្នកនឹងអាចចូលទៅ (Log In) កាន់វេបផតថល ដើម្បីទទួលបានស្ថានភាពចុងក្រោយនៃការស្នើសុំ។ សូមរង់ចាំយ៉ាងយូរ ៨ ម៉ោង នៃម៉ោងធ្វើការ ដើម្បីមន្ត្រីមានសមត្ថកិច្ច ផ្ទៀងផ្ទាត់ និង ត្រួតពិនិត្យពាក្យស្នើសុំរបស់លោកអ្នក។



## ៥.២.២. មុខងារទាញយកវិញ្ញាបនបត្រ

- ចុចលើរូបរបស់លោកអ្នក នៅផ្នែកខាងស្តាំ ខាងលើនៃផតថល រួចចុច “ប្រវត្តិរូបរបស់ខ្ញុំ”។





- ចុច "ពិនិត្យវិញ្ញាបនបត្រ" រួចចុច "ទាញយក"។



# ៥.២.៣. មុខងារផ្លាស់ប្ដូរកូដសម្ងាត់

- ចុចលើរូបរបស់លោកអ្នក នៅផ្នែកខាងស្ដាំ ខាងលើនៃផតថល រួចចុច **"ការកំណត់គណនី"**។




- ចុច ✎ រួចបញ្ចូលអ៊ីម៉ែល/លេខទូរស័ព្ទទំនាក់ទំនង, បង្កើតលេខសម្ងាត់ថ្មី និង បញ្ជាក់លេខសម្ងាត់ថ្មី រួចចុចរួចចុច **"បន្ទាប់"** ជាការស្រេច។



## ៥.២.៤. ទំព័រដើម

នៅលើទំព័រដើមនៃផតថល, លោកអ្នកនឹងអាចតាមដានស្ថានភាពនៃពាក្យស្នើសុំ និង តាមដានសេចក្តីជូនដំណឹង និង ព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។



## ៥.២.៥. ជំនួយ

- ចុចលើរូបរបស់លោកអ្នក នៅផ្នែកខាងស្ដាំ ខាងលើនៃរេបផតថល រួចចុច **“ជំនួយ”** ដើម្បីស្វែងរកមធ្យោបាយទាក់ទងមកកាន់ក្រុមការងារ ក្នុងករណីមានចម្ងល់ ឬ បញ្ហាផ្សេងៗ។



## ៥.២.៦. ដំណឹង

- ចុច 🔔 នៅផ្នែកខាងស្តាំ ខាងលើនៃផតថល ដើម្បីទទួលបានដំណឹងផ្សេងៗ។



## ៥.២.៧. ការកំណត់

- ចុចលើរូបរបស់លោកអ្នក នៅផ្នែកខាងស្តាំ ខាងលើនៃផតថល រួចចុច **“ចាកចេញ”** ដើម្បីចាកចេញ **(Log Out)** ពីគណនីរបស់លោកអ្នក។



## អភិវឌ្ឍ និង រៀបចំដោយ

## សហការជាមួយ

Wing Bank

អេស៊ីលីដា ACLEDA BANK


### សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងទៅកាន់៖

(+855) 00 000 000

(+855) 00 000 000

ច្បាលចុះឈ្មោះប្រជាជនក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ

ច្បាលចុះឈ្មោះប្រជាជនក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ

### អាស័យដ្ឋាន៖

អគារមជ្ឍមណ្ឌលអភិវឌ្ឍធុរកិច្ច, ផ្លូវមហាវិថី OCIC, សង្កាត់ជ្រោយចង្វារ,
ខណ្ឌជ្រោយចង្វារ, រាជធានីភ្នំពេញ, ប្រទេសកម្ពុជា